# បទអន្តរាគមន៍

## ថ្លែងដោយលោកស្រី Annette Dixon នាយិកាធនាគារពិភពលោកប្រចាំកម្ពុជា

## តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

## រាជធានីភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១០

សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមគោរពឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន

ក្នុងនាមដៃគូអភិវឌ្ឍន៍នៃរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងការចូលរួមមតិក្នុងពិធីបើកវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី៣នេះ។ ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសចំពោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក) ដែលដឹកនាំដោយឯកឧត្តម **ឈាង យ៉ាណារ៉ា** ដែលបានសម្របសម្រួលរៀបចំព្រឹត្តិការណ៍នេះបានយ៉ាងល្អប្រសើរ។ ជាពិសេស យើងខ្ញុំសូមកោតសរសើរដោយស្មោះចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានមកធ្វើជាអធិបតីភាពដោយផ្ទាល់ក្នុងវេទិកានេះ ហើយយើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងសុន្ទរកថារបស់ឯកឧត្តមអំពីរបៀបវារៈសម្រាប់ពិភាក្សារបស់យើងនៅក្នុងរយៈពេលពីរថ្ងៃនេះ។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព!**

គោលបំណងសំខាន់ដែលយើងទាំងអស់គ្នាមកជួបជុំគ្នានៅថ្ងៃនេះ គឺដើម្បីធានាការលើកកំពស់សុខមាលភាពរបស់ប្រជាជនកម្ពុជាទាំងអស់ និងជាពិសេស គឺការផ្តល់ឱកាសនានាសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះក្នុងការរស់នៅប្រកបដោយសុខភាពល្អ និងមានសុភមង្គលនាពេលបច្ចុប្បន្ន ក៏ដូចជាសម្រាប់ពេលអនាគត។ ការរួមចំណែកក្នុងការសម្រេចបានជោគជ័យនូវគោលបំណងនេះ គឺអាស្រ័យលើការពង្រឹងភាពជាដៃគូរបស់យើង។ ការរៀបចំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា គឺជាព្រឹត្តិការណ៍មួយដ៏សំខាន់ក្នុងការពង្រឹងភាពជាដៃគូរបស់យើង តាមរយៈការផ្តល់ឱកាសឱ្យយើងទាំងអស់គ្នាធ្វើការពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាយ៉ាងស្និទ្ធស្នាល ការវាយតម្លៃក្នុងន័យស្ថាបនាលើវឌ្ឍនភាពនៃសមិទ្ធផលអភិវឌ្ឍន៍ដែលសម្រេចបាន និងធានាឱ្យមានតម្លាភាព និង

គណនេយ្យភាព ចំពោះភាគីពាក់ព័ន្ធទាំងអស់របស់យើង រួមទាំងអ្នកទទួលផល ដែលជាប្រជាពលរដ្ឋកម្ពុជា។

សម្រាប់មតិចូលរួមរបស់ខ្ញុំក្នុងពិធីបើកនេះ ខ្ញុំសូមអនុញ្ញាតិលើកឡើងដោយសង្ខេបអំពីបញ្ហាប្រឈមនានា ដែលប្រទេសកម្ពុជាកំពុងជួបប្រទះ តួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ទល់ដោះស្រាយជាមួយនឹងបញ្ហាប្រឈមទាំងនេះ និងមធ្យោបាយ ដែលភាគីពាក់ព័ន្ធនានាអាចជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមមានដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនទាំងអស់ ដែលកំពុងមានវត្តមាននៅទីនេះ។

ក្នុងទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពជាច្រើនលើកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងបទពិសោធន៍នៃបញ្ហាអតិផរណាតម្លៃប្រេង និងតម្លៃស្បៀងអាហារ ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក បានធ្វើឱ្យប្រទេសកម្ពុជាក៏ដូចជាប្រទេសដទៃទៀតនៅក្នុងពិភពលោក ជួបប្រទះនូវការលំបាកជាច្រើនក្នុងពេលថ្មីៗកន្លងមកនេះ។ ជាលទ្ធផល ក្នុងឆ្នាំកន្លងមកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានរងនូវផលប៉ះពាល់ជាខ្លាំង ដែលធ្វើឱ្យប្រជាជនកម្ពុជាក្រីក្រ និងក្រុមជនងាយរងគ្រោះជាច្រើនជួបប្រទះនូវការលំបាកកាន់តែខ្លាំងឡើង។ ទោះបីកំណើនសេដ្ឋកិច្ចត្រូវបានគេរំពឹងថា នឹងងើបឡើងវិញនៅក្នុងឆ្នាំ២០១០យ៉ាងណាក៏ដោយ ក៏មានប្រជាជនកម្ពុជាប្រមាណជា៤លាននាក់ស្ថិតក្នុងភាពក្រីក្រ និងមានប្រជាជនជាច្រើនទៀត ដែលកំពុងរស់នៅកៀកនឹងខ្សែបន្ទាត់នៃភាពក្រីក្រ។ ជាងនេះទៀតនៅមានគម្លាតគ្នាខ្លាំងក្នុងប្រទេសកម្ពុជា រវាងអ្នកមាននិងអ្នកក្រ និងរវាងអ្នករស់នៅតំបន់ជនបទ និងនៅទីប្រជុំជន និងជាពិសេសជីវភាពរស់នៅរបស់គ្រួសារភាគច្រើននៅតាមទីជនបទ ដែលនៅតែរងគ្រោះដោយសារវិបត្តនេះ កំពុងបន្តជួបប្រទះនូវបញ្ហាប្រឈមជាច្រើន។ ភាពក្រីក្រនេះ ធ្វើឱ្យកុមារខ្វះអាហារូបត្ថម្ភ លទ្ធផលការសិក្សាធ្លាក់ចុះ អត្រាមរណៈមាតាបន្ទាប់ពីសម្រាលកូននៅមានកំរិតខ្ពស់ និងការខ្វះអនាម័យ និងការផ្គត់ផ្គង់ទឹកនៅទីជនបទ។ យើងទាំងអស់គ្នានឹងបានដឹងពីបញ្ហាប្រឈមទាំងនេះបន្ថែមទៀតនៅរបៀបវារៈទីមួយអំពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់អំពីវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មរបស់ខ្លួន។ ដូចដែលយើងបានពិភាក្សានៅក្នុងរបៀបវារៈទី២នាថ្ងៃនេះ ចំណុចសំខាន់នៅក្នុងយុទ្ធសាស្ត្រចតុកោណ គឺការធ្វើពិពិធកម្ម និងការលើកកំពស់ភាពប្រកួតប្រជែងនៅក្នុងវិស័យសេដ្ឋកិច្ច ក៏ដូចជាការផ្តល់កិច្ចគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋក្រីក្រ និង

ក្រុមជនងាយរងគ្រោះនានា។ ពាក់ព័ន្ធនឹងចំណុចនេះ ដៃគូអភិវឌ្ឍន៍ទាំងអស់ សូមធ្វើការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា អំពីវឌ្ឍនភាពនាពេលបច្ចុប្បន្នក្នុងការពង្រឹងកិច្ចគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះ និងសង្ឃឹមទទួលនូវការធ្វើបច្ចុប្បន្នភាពស្តីពីការអនុម័តយុទ្ធសាស្ត្រ និងជំហ៊ានបន្ទាប់នានា សម្រាប់ការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍។

មូលដ្ឋានគ្រឹះមួយក្នុងចំណោមមូលដ្ឋានគ្រឹះនានាសម្រាប់ការលើកកំពស់ផលិតភាព និងពិពិធកម្មកសិកម្ម គឺតាមរយៈការធានាការប្រើប្រាស់ដីធ្លី ព្រមទាំងការប្រើប្រាស់ និងគ្រប់គ្រងធនធានដីរបស់រដ្ឋប្រកបដោយប្រសិទ្ធភាព។ ទាក់ទងនឹងបញ្ហានេះ ដៃគូអភិវឌ្ឍន៍សង្ឃឹមថា នឹងមានការពិភាក្សាប្រកបដោយផ្លែផ្កា និងក្នុងន័យស្ថាបនាលើបញ្ហាទាំងនេះ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំក៏សូមធ្វើការកោតសរសើរ ដោយស្មោះចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុម័តលើកម្មវិធីគ្រប់គ្រងព្រៃឈើជាតិ និងសកម្មភាពនៃការបង្ក្រាប ការកាប់ឈើខុសច្បាប់នាពេលថ្មីៗនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដែលបានរៀបចំឡើង ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្ររយៈពេលវែងមួយសម្រាប់វិស័យរុក្ខាប្រមាញ់ទទួលបាននូវការអបអរសាទរយ៉ាងខ្លាំងពីគ្រប់មជ្ឈដ្ឋាន ព្រោះថាការអនុវត្តយុទ្ធសាស្ត្រនេះនឹងនាំមកនូវការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានព្រៃឈើ។

ជាងនេះទៀត បញ្ហានៃផលប៉ះពាល់ជាសក្តានុពលនានាបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ មកលើកំណើនសេដ្ឋកិច្ចនាពេលអនាគតរបស់ប្រទេសកម្ពុជា ភាពថ្កុំថ្កើង និងការរស់នៅរបស់ប្រជាជនកម្ពុជា នឹងត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងក្នុងការពិភាក្សាអំពីវិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក និងការប្រើប្រាស់ដីធ្លី។ ពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ មានឱកាសជាច្រើនសម្រាប់ការផ្តល់ហិរញ្ញប្បទាន ដើម្បីជួយគាំទ្រដល់ប្រទេសកម្ពុជា ដើម្បីធ្វើការសម្របសម្រួលទៅនឹងបម្រែបម្រួលអាកាសធាតុ និងសម្រាប់លើកកំពស់ជម្រើសនានាក្នុងការប្រើប្រាស់ជាតិកាបូនដែលមានកិរិតទាប **"ធ្វើឱ្យមានពណ៌បៃតង"** និងទាមទារអោយមានការរៀនបចំនូវវិធីសាស្ត្ររួមមួយសម្រាប់រដ្ឋាភិបាលទាំងមូល ដោយបញ្ចូលទាំងសង្គមស៊ីវិល និងវិស័យឯកជនផងដែរ។ ពាក់ព័ន្ធនឹងការងារនេះ ដៃគូអភិវឌ្ឍន៍ទាំងអស់ ត្រៀមខ្លួនជាស្រេចក្នុងការពិភាក្សាបន្ថែមទៀតជាមួយរាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយនូវផលប៉ះពាល់នានា ដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុនេះ។

ជាការពិត ការដោះស្រាយនូវបញ្ហាប្រឈមទាំងនេះដោយរដ្ឋាភិបាល គឺពិតជាមានសារសំខាន់ដូចមធ្យោបាយដែលប្រើប្រាស់ក្នុងការដោះស្រាយនូវបញ្ហាប្រឈមទាំងនេះដែរ។ ចំណុចនេះ គឺជាប្រធានបទទី៣ ដែលយើងទាំងអស់គ្នានឹងត្រូវធ្វើការពិភាក្សាបន្ថែមលើកកំណែទម្រង់ជាគន្លឹះនានា ដែលរាជរដ្ឋាភិបាលកំពុងតែអនុវត្ត។ កំណែទម្រង់ទាំងនេះរួមមាន ការធ្វើវិមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារកំណែទម្រង់មន្ត្រីរាជការស៊ីវិល។ រហូតមកទល់ពេលនេះ មានវឌ្ឍនភាពមួយចំនួននៅក្នុងកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការពង្រឹងបន្ថែមលើការងារគណនេយ្យភាព និងតម្លាភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន

ធម្មជាតិរបស់ប្រទេសកម្ពុជាគឺជាមូលដ្ឋានគ្រឹះសម្រាប់ធានាការរីកលូតលាស់សំរាប់ជនទូទៅនិងប្រកបដោយចិរភាព។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអបអរសាទររាជរដ្ឋាភិបាលកម្ពុជាចំពោះសមិទ្ធិផលសំខាន់ៗនានាដែលសម្រេចបានពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកិច្ចខិតខំប្រឹងប្រែងទាំងឡាយក្នុងការលើកកំពស់សុខដុមនីយកម្ម និងការបន្សុីគ្នាក្នុងចំណោមដៃគូអភិវឌ្ឍន៍ សម្រាប់ការអនុវត្តនានាក្នុងពេលអនាគត។

ជាមួយគ្នានេះដែរ ដៃគូអភិវឌ្ឍន៍ក៏ត្រូវយកចិត្តទុកដាក់ផងដែរលើសមិទ្ធិផលសំខាន់ៗ នៃការប្រកាសឱ្យប្រើប្រាស់នូវច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ និងច្បាប់ព្រហ្មទណ្ឌ។ នេះគឺជា គុណសម្បត្តិមួយដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងអំពើពុករលួយ ដែលជាការងារស្នូល នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ ការងារសំខាន់បន្ទាប់ទៀត គឺធានាឱ្យមានការរៀបចំក្របខ័ណ្ឌគតិយុត្ត ស្ថាប័ន និងដំណើរការផ្សេងៗទៀត ហើយដៃគូអភិវឌ្ឍន៍ត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រដល់រាជរដ្ឋាភិបាលលើការងារនេះ។

កំណែទម្រង់សំខាន់នីមួយៗទាំងនេះបញ្ជាក់នូវការផ្លាស់ប្តូរសំខាន់ៗនៅក្នុងរដ្ឋាភិបាលទាំងមូល។ កំណែទម្រង់ទាំងនេះពឹងផ្អែកគ្នាទៅវិញទៅមក ផ្តល់នូវភាពជោគជ័យមួយដែលមានឥទ្ធិពលដល់ការរីកចំរើនក្នុងវិស័យដទៃទៀត។ ជាការពិតណាស់ ការអនុវត្តជោគជ័យនូវគម្រោងកំណែទម្រង់ជាទូទៅរបស់រដ្ឋាភិបាល តម្រូវឱ្យមាននូវវិធីសាស្ត្រដែលអនុវត្តដោយរាជរដ្ឋាភិបាលទាំងមូល។ លទ្ធផលអភិវឌ្ឍន៍ជាច្រើននឹងនៅតែមិនអាចសម្រេចទៅបាន ដរាបណាគ្មានការទំនាក់ទំនង និងការសម្របសម្រួលយ៉ាងជិតស្និត រវាងទីភ្នាក់ងារថ្នាក់ជាតិសំខាន់ៗ និងរវាងក្រសួងស្ថាប័នសំខាន់ៗ ជាមួយនឹងក្រសួងស្ថាប័នជំនាញនានានោះទេ។

នៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានាពេលកន្លងទៅ ចំណុចគន្លឹះក្នុងការពិភាក្សាបានផ្តោតលើសារសំខាន់នៃវិធីសាស្ត្រធ្វើអោយមានសមារណកម្មកាន់តែប្រសើរឡើង ដើម្បីធានាថាធនធានក្នុងស្រុក និងពីប្រភពបរទេស ត្រូវបានប្រើប្រាស់ចំទិសដៅ និងប្រកបដោយប្រសិទ្ធភាព ដើម្បីឈានទៅការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ផ្អែកលើការសន្យាដែលបានធ្វើឡើងនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមនូវដំណើរការមួយ ដើម្បីធ្វើសមាហរណកម្មក្នុងការកសាងផែនការយុទ្ធសាស្ត្រ ការរៀបចំថវិកា និងការគ្រប់គ្រងជំនួយ ប៉ុន្តែវឌ្ឍនភាពនៃការងារទាំងនេះនៅមានកំរិតនៅឡើយ។ វាមានសារសំខាន់ណាស់សំរាប់រាជរដ្ឋាភិបាលដើម្បីនាំមុខក្នុងការសម្រួលធនធានឱ្យស្របស្របនឹងអាទិភាពការអភិវឌ្ឍ និងសំរាប់ដៃគូអភិវឌ្ឍន៍ ដើម្បីធានាថាជំនួយរបស់យើងត្រូវគ្នានឹងផែនការជាតិ ព្រមទាំងមិនធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងរបស់យើងមិនអាចប្រមូលផ្តុំជាធ្លុងមួយបាន។

ខ្ញុំសូមធ្វើការសន្និដ្ឋានលើចំណុចសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងមធ្យោបាយ នានាដែលដៃគូអភិវឌ្ឍន៍ត្រូវធ្វើការរួមគ្នាដើម្បីជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានារបស់រាជរដ្ឋាភិបាល។ យើងទាំងអស់គ្នា ត្រូវផ្តោតការយកចិត្តទុកដាក់លើអ្នកទទួលផលពីកិច្ចអភិវឌ្ឍន៍។ លទ្ធផលទាំងឡាយនៃការអភិវឌ្ឍ គឺសម្រាប់ប្រជាជន ហើយ

សម្លេង និងសេចក្ដីត្រូវការនានារបស់ពួកគាត់ គឺជាមូលដ្ឋានសម្រាប់តម្រង់ទិសភាពជាដៃគូរបស់យើង ដើម្បីធ្វើឱ្យសម្រេចបាននូវលទ្ធផលទាំងនោះ។ ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីបានឃើញស្រាប់ហើយថា មានបញ្ហាជាច្រើនបានបញ្ចូលក្នុងរបៀបវារៈនៃវេទិការបស់យើង ដែលបង្ហាញពីភាពស៊ាំញ៉ាំនៃបញ្ហាប្រឈមពាក់ព័ន្ធកិច្ចអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ប៉ុន្តែចំពោះដៃគូអភិវឌ្ឍន៍នៅតែរក្សាការសន្យារបស់ខ្លួនយ៉ាងមុតមាំ ក្នុងការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ។ ផលវិបាកមួយទៀតនៃវិបត្តិសេដ្ឋកិច្ចពិភពលោក គឺការកើនឡើងនៃសំពាធមូលនិធិមានស្រាប់សំរាប់ជំនួយអភិវឌ្ឍន៍ ដែលប្រែជាមានតំរូវការខ្ពស់ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពជំនួយ និងគណនេយ្យភាពសំរាប់លទ្ធផល។ ជាមួយគ្នានេះដែរ ដៃគូអភិវឌ្ឍន៍ទាំងអស់នៅតែប្ដេជ្ញាក្នុងការលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍នៅក្រោមការដឹកនាំរបស់រដ្ឋាភិបាល។

ក្រុមការងារបច្ចេកទេសនានា គឺជាយន្តការដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការប្រចាំថ្ងៃ ហើយយើងខ្ញុំសូមធ្វើការកោតសរសើរចំពោះការងារ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់មន្ត្រីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលជាសមាជិកក្រុមការងារនេះ។

យើងខ្ញុំសង្ឃឹមថា យើងនឹងធ្វើការជាមួយគ្នាលើសូចនាករតាមដានត្រួតពិនិត្យរួមគ្នាសម្រាប់ឆ្នាំ២០១០ និង ២០១១ ដោយផ្ដោតការយកចិត្តទុកដាក់លើសមិទ្ធផលដែលត្រូវសម្រេច។ ដៃគូអភិវឌ្ឍន៍ សូមធ្វើការគាំទ្រចំពោះការផ្ដោតការយកចិត្តទុកដាក់ជាបន្តរបស់រាជរដ្ឋាភិបាល ទៅលើការលើកកំពស់ការត្រួតពិនិត្យតាមដានរួមគ្នា ទាំងលើសូចនាករតាមដានត្រួតពិនិត្យ ក៏ដូចជាសម្រាប់កិច្ចសហប្រតិបត្តិការទាំងអស់របស់យើងខ្ញុំជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឱ្យកិច្ចខិតខំប្រឹងប្រែងរបស់យើងប្រែក្លាយទៅជាផលប្រយោជន៍ជាក់ស្ដែងសម្រាប់ប្រជាជនកម្ពុជា។ យើងខ្ញុំក៏រំពឹងថានឹងប្រើប្រាស់ការពិភាក្សារយៈពេលពីរថ្ងៃបន្ទាប់ទៀត ដើម្បីរិះរកមធ្យោបាយផ្សេងៗ សំដៅពង្រឹងក្របខ័ណ្ឌភាពជាដៃគូរបស់យើង និងលើកកំពស់ការតាមដានត្រួតពិនិត្យលើអាទិភាព គោលនយោបាយនានាដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបច្ចុប្បន្ននេះក្រុមការងារបច្ចេកទេស និងយន្តការតាមដានត្រួតពិនិត្យសូចនាកររួមគ្នានៅមានកំរិត ។

យើងខ្ញុំក៏សូមអរគុណចំពោះឯកសារស្ដីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានលើកឡើងសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១០ ហើយឯកសារនេះបានចូលរួមចំណែកយ៉ាងសំខាន់កក្នុងកិច្ចពិភាក្សារបស់យើង ហើយយើងខ្ញុំសង្ឃឹមថា យើងនឹងបន្តពង្រឹងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងកិច្ចពិភាក្សាអំពីការអភិវឌ្ឍនានា។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះការចូលរួមរបស់វិស័យឯកជននៅក្នុងវេទិកានេះ ហើយសង្ឃឹមថា លទ្ធផលនៃកិច្ចពិភាក្សានេះ នឹងចូលរួមចំណែកជាមួយសមិទ្ធិផលនៃវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជនដែលបានធ្វើឡើងកាលពីថ្ងៃទី២៧ ខែមេសា កន្លងទៅនេះ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីគោរព! ក្នុងនាមដៃគូអភិវឌ្ឍន៍ទាំងអស់ ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់បទអន្តរាគមន៍របស់ខ្ញុំ ហើយសង្ឃឹមថា កិច្ចពិភាក្សារបស់យើងក្នុងរយៈពេល២ថ្ងៃខាងមុខនេះ នឹងផ្តល់នូវលទ្ធផលល្អប្រសើរសម្រាប់ពង្រឹងបន្ថែមលើភាពជាដៃគូរបស់យើង ដើម្បីឈានទៅសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍នានា។

**សូមអរគុណ!**